# តើមានបញ្ហាក្នុងការបង់វិក្កយបត្រថាមពលរបស់អ្នកឬ?

## ជំនួយគឺមានផ្តល់ជូននៅពេលណាដែលអ្នកត្រូវការវា

### ការបង់វិក្កយបត្រថាមពលរបស់អ្នក

ប្រសិនបើអ្នកមានការលំបាកក្នុងការបង់វិក្កយបត្រ មានជំនួយសម្រាប់អ្នកក្នុងការបង់វិក្កយបត្ររបស់អ្នក។ អ្នកគ្រាន់តែទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នកប៉ុណ្ណោះ។

នៅរដ្ឋវិចថូរៀ រដ្ឋាភិបាលមានបទប្បញ្ញត្តិនានាដើម្បីធ្វើឱ្យប្រាកដថាក្រុមហ៊ុនថាមពលលក់រាយត្រូវតែជួយនរណាម្នាក់ ដែលមានការលំបាកក្នុងការបង់វិក្កយបត្ររបស់ខ្លួន។

### គេមិនអាចបណ្តាច់សេវាផ្គត់ផ្គង់សម្រាប់អ្នកបានទេ ប្រសិនបើមានការអនុវត្តករណីយ៉ាងហោចណាស់មួយក្នុងចំណោមករណីខាងក្រោមនេះចំពោះអ្នក៖

< $300

អ្នកជំពាក់ក្រុមហ៊ុនថាមពលលក់រាយរបស់អ្នកតិចជាង $300

អ្នកកំពុងធ្វើការបង់ប្រាក់ជាទៀងទាត់លើគម្រោងបង់ប្រាក់បណ្តាក់មួយ

អ្នកបានដាក់ពាក្យស្នើសុំប្រាក់ជំនួយសង្គ្រោះសម្រាប់សេវាកម្មចាំបាច់ (Utility Relief Grant)

### គម្រោងបង់ប្រាក់បណ្តាក់

គឺជាវិធីដ៏ល្អមួយដើម្បីគ្រប់គ្រងការចំណាយរបស់អ្នក។ គម្រោងបង់ប្រាក់អនុញ្ញាតឱ្យអ្នកបង់ប្រាក់ចំនួនតិចជាង និងទៀងទាត់ជាងមុន។ ឧទាហរណ៍ ការបង់ប្រាក់រៀងរាល់ពីរសប្តាហ៍ម្តង ជាជាងការបង់វិក្កយបត្ររបស់អ្នកទាំងអស់ជារៀងរាល់ខែ។ មិនមានការចំណាយបន្ថែមសម្រាប់ការបង់ប្រាក់ជាមួយនឹងគម្រោងបង់ប្រាក់បណ្តាក់នោះទេ។

### Centrepay

ជាគម្រោងបង់ប្រាក់ដោយស្វ័យប្រវត្តិដែលអ្នកអាចរៀបចំបាន ប្រសិនបើអ្នកទទួលបានប្រាក់ឧបត្ថម្ភពី Centrelink ។ Centrepay គឺមិនគិតថ្លៃទេ ហើយអនុញ្ញាតឱ្យអ្នកធ្វើការបង់វិក្កយបត្រថាមពលជាទៀងទាត់ចេញពីប្រាក់ឧបត្ថម្ភពី Centrelink របស់អ្នក។ សូមពិភាក្សាជាមួយក្រុមហ៊ុនថាមពលលក់រាយរបស់អ្នកអំពីការរៀបចំនេះ។

### ប្រាក់ជំនួយសង្គ្រោះសម្រាប់សេវាកម្មចាំបាច់ (Utility Relief Grant)

គឺជាប្រាក់ឧបត្ថម្ភ $650 សម្រាប់អ្នកកាន់ប័ណ្ណសម្បទានដែលមានការលំបាកផ្នែកហិរញ្ញវត្ថុ ដើម្បីជួយពួកគេបង់វិក្កយបត្រដែលនៅជំពាក់។



VICTORIA State Government
Environment, Land, Water and Planning

## ចុះបើខ្ញុំនៅជំពាក់ប្រាក់វិក្កយបត្រមុន?

### ខ្ញុំអាចបង់វិក្កយបត្របន្ទាប់របស់ខ្ញុំ៖

ទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ហើយរៀបចំគម្រោងមួយក្នុងការបង់ប្រាក់បណ្ដាក់ ដើម្បីជួយអ្នកបង់វិក្កយបត្រដែលអ្នកមិនបានបង់ពីគ្រាមុន។

គម្រោងបង់ប្រាក់បណ្ដាក់របស់អ្នក អាចបង់រម្លស់ចំនួនប្រាក់ដែលអ្នកជំពាក់ដែលត្រូវបង់សងក្នុងរយៈពេលពីរឆ្នាំ។

### ខ្ញុំមិនអាចមានលទ្ធភាពបង់វិក្កយបត្របន្ទាប់របស់ខ្ញុំបានទេ៖

សូមហៅទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក។ ពួកគេចាំបាច់ត្រូវតែជួយអ្នកក្នុងការ៖

- រៀបចំការបង់ប្រាក់បណ្ដាក់ជាទៀងទាត់មួយ សម្រាប់ចំនួនប្រាក់ដែលអ្នកអាចបង់បាន
- ផ្អាកការបង់ប្រាក់ណាមួយចំពោះចំនួនប្រាក់ដែលអ្នកនៅជំពាក់វិក្កយបត្រពីមុន
- ផ្ដល់ដំបូន្មានអំពីគម្រោងថាមពលណាមួយរបស់ពួកគេដែលមានតម្លៃថោកបំផុតសម្រាប់ផ្ទះរបស់អ្នក
- ផ្ដល់សម្បទានថាមពល និងផ្ដល់ប្រាក់ជំនួយសង្គ្រោះ

## ខ្ញុំអត់មានជំពាក់ប្រាក់វិក្កយបត្រពីមុនទេ ប៉ុន្តែចុះបើខ្ញុំមិនអាចបង់វិក្កយបត្របន្ទាប់ទៀត?

ហៅទូរសព្ទទៅក្រុមហ៊ុនថាមពលលក់រាយរបស់អ្នក ដើម្បីរៀបចំគម្រោងមួយដើម្បីបង់ប្រាក់បណ្ដាក់ ឬពន្យារកាលបរិច្ឆេទដែលអ្នកត្រូវបង់។ ពួកគេចាំបាច់ត្រូវតែជួយអ្នក៖

រៀបចំការបង់ប្រាក់បណ្ដាក់ជាទៀងទាត់មួយ សម្រាប់ចំនួនប្រាក់ដែលអ្នកអាចបង់បាន។

ទទួលដំបូន្មានអំពីគម្រោងថាមពលណាមួយរបស់ពួកគេ ដែលមានតម្លៃថោកបំផុតសម្រាប់ផ្ទះរបស់អ្នក។

ទទួលសម្បទានថាមពល និងប្រាក់ជំនួយសង្គ្រោះសូមទូរសព្ទទៅអាជ្ញាធរដោះស្រាយបណ្ដឹងតវ៉ាពីពលរដ្ឋអំពីថាមពល

## បើក្រុមហ៊ុនថាមពលលក់រាយរបស់ខ្ញុំមិនផ្ដល់ជំនួយដល់ខ្ញុំ នៅពេលខ្ញុំត្រូវការ?

សូមទូរសព្ទទៅអាជ្ញាធរដោះស្រាយបណ្ដឹងតវ៉ាពីពលរដ្ឋអំពីថាមពល និងទឹក (Energy and Water Ombudsman)។ អាជ្ញាធរដោះស្រាយបណ្ដឹងតវ៉ាពីពលរដ្ឋ (Ombudsman) គឺជាសេវាកម្មឥតគិតថ្លៃដើម្បីជួយដោះស្រាយវិវាទនានា។ គ្រាន់តែទូរសព្ទទៅលេខ **1800 500 509** ហើយត្រៀមរៀបចំវិក្កយបត្រថាមពលរបស់អ្នកឱ្យបានរួចរាល់ជាការស្រេច។



VICTORIA State Government
Environment, Land, Water and Planning